While it took only about two months to dismantle and transport the house, it took eight months to painstakingly reconstruct it. The same Khmer carpenters who had taken it apart and travelled with the wood were on hand to rebuild it. Darryl describes their contribution, saying, "The group of Khmer carpenters did the most magnificent job. It was the same team from start to finish. It is a real tribute to these people."

The house that once upon a time resided on an island in Kampong Cham can now be found in Siem Reap as a fully functional residence, only slightly modified to make it more suitable for modern living.

It is truly magnificent. Despite its age, the dark wood still maintains a sense of richness and grandeur. The structure is supported by large columns that have been decorated and lacquered by hand. Both the screen inside the house and the outside window shutters and doors bear breathtaking pastoral carvings of flowers and fruits, clearly crafted with great care and detail. Silhouetted fretwork runs around the entire building, letting in air and breezes from the large terrace. Looking down at the house's slated floor, one marvels at how each narrow board was taken up and nailed back into place piece by piece.

ខណៈពេលដែលវាប្រើពេលតែប្រហែលជាពីរខែដើម្បីដោះនិងដឹកផ្ទះនេះ វាចំណាយពេលដល់ទៅប្រាំបីខែដើម្បីសាងវាឡើងវិញទាំងលំបាក។ ជាងឈើខ្មែរ ដែលបានដោះផ្ទះនេះជាបំណែកៗ និងបានធ្វើដំណើរជាមួយនឹងឈើទាំងនេះ មានវត្តមានក្នុងការកសាងវាឡើងវិញ។ លោក ដារីល រៀបរាប់ពីការចូលរួមរបស់ពួកគេ ដោយនិយាយថា "ក្រុមជាងឈើខ្មែរនេះធ្វើការល្អបំផុត។ គឺជាក្រុមដដែលចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់។ វាជាវិភាគទានពិតប្រាកដមួយរបស់អ្នកទាំងនេះ"។

ផ្ទះនេះដែលធ្លាប់មានទីតាំងនៅលើកោះមួយក្នុងខេត្តកំពង់ចាម ឥឡូវនេះ គេអាចឃើញនៅខេត្តសៀមរាបហើយ ក្នុងនាមជានិវេសដ្ឋានមួយដែលដំណើរការបានពេញលេញ ដោយគ្រាន់តែមានការកែប្រែបន្តិចដើម្បីឱ្យវាសក្តិសមជាមួយនឹងការរស់នៅបែបទំនើប។

វាប្រាកដជាវិសេសវិសាលណាស់។ ទោះជាមានអាយុច្រើន ឈើខ្មៅរបស់ផ្ទះនេះនៅល្អដដែល។ រចនាសម្ព័ន្ធនេះទ្រដោយសរសរធំៗ ដែលតុបតែងនិងលាបម្រ័ក្សណ៍ ដោយប្រើដៃ។ របាំងនៅក្នុងផ្ទះ និង ខាងក្រៅបង្អួច និង ទ្វារ មានក្បាច់ទិដ្ឋភាពស្រែចម្ការយ៉ាងចាប់ចិត្តនៃផ្កានិងផ្លែឈើ ដែលឆ្លាក់ឡើងយ៉ាងច្បាស់ ជាមួយនឹងការយកចិត្តទុកដាក់យ៉ាងល្អិតល្អន់។ ក្បាច់ស្រមោលមានទៅពាសពេញអគារទាំងមូល នាំខ្យល់ជំនោរចូលពីជម្រាលដ៏ធំធេង។ សម្លឹងមើលទៅកម្រាលបន្ទះឈើ គេមានការស្ងើចសរសើរចំពោះការដែលបន្ទះក្តារនីមួយៗត្រូវគេលើកចេញ និង វាយចូលទៅកន្លែងដើមវិញ ម្តងមួយៗ។









Reflecting on the process that brought him his new home, Darryl could not be happier: "When I saw the house being dismantled from its original site, I had a bit of a shock. But I shouldn't have had doubt. Sokol had the confidence it was going to work out. As it turned out, it was a great success. I am deeply in love with the house."

ឆ្លុះបញ្ចាំងពីដំណើរការដែលនាំគាត់មកកាន់ផ្ទះថ្មីរបស់គាត់ លោក ដារីល មិនអាចសប្បាយចិត្តជាងនេះទៀតឡើយ: "ពេលដែលខ្ញុំឃើញផ្ទះនេះកំពុងត្រូវគេដោះចេញពីទីតាំងដើម ខ្ញុំមានអារម្មណ៍ស្រឡាំងកាំងបន្តិច។ ប៉ុន្តែ ខ្ញុំមិនគួរមានមន្ទិលឡើយ។ សុកលមានជំនឿចិត្តថា នឹងអាចធ្វើវាបាន។ ដូចឃើញអញ្ចឹង វាគឺជាជោគជ័យដ៏អស្ចារ្យមួយ។ ខ្ញុំលង់ស្នេហ៍យ៉ាងជ្រៅជាមួយនឹងផ្ទះនេះ"។

"ITS DARK WOOD STILL MAINTAINS A SENSE OF RICHNESS AND GRANDEUR"





